ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ
លេខៈ.........................................

## ឯកសារជំនួយស្មារតី

យោងតាមគេហទំព័រសារព័ត៌មាន FreshNews ចុះថ្ងៃទី ១០ ខែកក្កដា ឆ្នាំ២០១៧ បានអោយដឹងថា ស្ថានទូតកម្ពុជាប្រចាំនៅម៉ាឡេស៊ី បានរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរ៩នាក់ ឲ្យវិលត្រឡប់មកស្រុកកំណើតវិញ បន្ទាប់ពីពួកគេមិនអាចទ្រាំទ្រជាមួយការងារបាន។

ហេតុដូចនេះហើយ ក្រុមការងារនាយកដ្ឋានស៊ើបអង្កេតពិសេស DSI នៃក្រសួងយុត្តិធម៌ថៃនៅកម្ពុជាគ្រោងនឹងទស្សនកិច្ច ពីថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី ០៣ ខែឧសភា ឆ្នាំ២០១៨ ដើម្បីជួបពិភាក្សាការងារ និងសាកសួរព័ត៌មានបន្ថែមជាមួយអាជ្ញាធរកម្ពុជា រួមមាននគរបាល និងមន្ត្រីពាក់ព័ន្ធ ដូចជាព្រះរាជអាជ្ញា និងមន្ត្រីសង្គមកិច្ច ដែលពាក់ព័ន្ធនឹងសំណុំរឿងជួញដូរពលករនេសាទកម្ពុជាចំនួន៥នាក់នោះ ១. លោក ហួន សែ (Mr. Se Huon) ២. លោក ហួន ស៊ឺ (Mr. Seu Huon) ៣. លោក ហួន ឈាង (Mr. Chheang) ៤. លោក ម៉ឹង ហាន់ (Mr. Han Moeng) និង ៥. លោក សែម សុធា (Mr. Sothea Sem)

ពលករចំនួន៥នាក់នោះ មកពីស្រុកសណ្តាន់ ខេត្តកំពង់ធំ ត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅធ្វើការនៅលើទូកនេសាទថៃ កាលពីឆ្នាំ២០១៦។ ដោយសារធ្វើការលំបាកពេក នៅពេលទូកនេសាទចូលចតកំពង់ផែនៅរដ្ឋ Sarawak ប្រទេសម៉ាឡេស៊ី នៅខែមករា ឆ្នាំ២០១៧ ពលករទាំង១៤នាក់បានលួចរត់ចេញពីទូក។ អាជ្ញាធរម៉ាឡេស៊ី ចាត់ទុកករណីនេះ ជាការជួញដូរមនុស្ស ហើយបានបញ្ជូនពលករទាំងនោះទៅរដ្ឋ Melaka ដើម្បីធ្វើការស៊ើបអង្កេតតាមនីតិវិធី។ សំណុំរឿង ត្រូវបានបញ្ចប់នៅដើមខែកក្កដា ឆ្នាំ២០១៧នេះ។

ក្នុងរយៈពេលស៊ើបអង្កេត ស្ថានទូតបានផ្តល់អ្នកបកប្រែ ជួបសួរសុខទុក្ខពលករ និងផ្តល់លិខិតបើកផ្លូវ ជូនពលករចំនួន២នាក់ ដែលពុំមានលិខិតឆ្លងដែន។ ពលករទាំង១៤រូប បានមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៧ វេលាម៉ោង១៥:៥៥នាទី តាមជើងយន្តហោះ AK534។ ក្នុងអំឡុងពេលរង់ចាំត្រឡប់មកកម្ពុជាវិញ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគសម្រាប់ពលការិនីទាំងពីរនាក់ខាងលើផងដែរ៕

**ឯកសារយោងៈ** www.freshnewsasia.com/index.php/en/localnews/59480-2017-07-10-09-16-31.html

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
======

# ស្ថានទូតកម្ពុជានៅម៉ាឡេស៊ី រៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរ១៦នាក់

------------

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេស**ម៉ាឡេស៊ី** បានអន្តរាគមដោះស្រាយបញ្ហា និងរៀបចំមាតុភូមិនិវត្តន៍របស់ពលករ-ពលការិនីខ្មែរចំនួន**១៦នាក់** តាមករណីដូចខាងក្រោម៖

**(១)** ពលករចំនួន**១៤នាក់** (ដូចមានរាយនាមភ្ជាប់ជាមួយ) មកពីស្រុកសណ្ដាន់ ខេត្តកំពង់ធំ ត្រូវបានមេខ្យល់បោកបញ្ឆោតនាំទៅធ្វើការនៅលើទូកនេសាទថៃ កាលពីឆ្នាំ២០១៦។ ដោយសារធ្វើការលំបាកពេក នៅពេលទូកនេសាទ ចូលចតកំពង់ផែនៅរដ្ឋSarawak ប្រទេសម៉ាឡេស៊ី នៅខែមករា ឆ្នាំ២០១៧ ពលករទាំង១៤នាក់បានលួចរត់ចេញពីទូក។ អាជ្ញាធរម៉ាឡេស៊ី ចាត់ទុកករណីនេះ ជាការជួញដូរមនុស្ស ហើយបានបញ្ជូនពលករទាំងនោះ ទៅរដ្ឋ Melaka ដើម្បីធ្វើការស៊ើបអង្កេតតាមនីតិវិធី។ សំណុំរឿង ត្រូវបានបញ្ចប់នៅដើមខែកក្កដា ឆ្នាំ២០១៧នេះ ។

ក្នុងរយៈពេលស៊ើបអង្កេត ស្ថានទូតបានផ្ដល់អ្នកបកប្រែ ជួបសួរសុខទុក្ខពលករ និងផ្ដល់លិខិតបើកផ្លូវ ជូនពលករចំនួន២នាក់ ដែលពុំមានលិខិតឆ្លងដែន។

ពលករទាំង**១៤**រូប បានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**០៩** ខែ**កក្កដា** ឆ្នាំ**២០១៧** វេលាម៉ោង**១៥:៥៥**នាទី តាមជើងយន្តហោះ **AK534** ។

**(២)** ពលការិនី ឈ្មោះ **ឡា ផល្លី** អាយុ៣៩ឆ្នាំ មកពីខេត្តសៀមរាប បានទៅម៉ាឡេស៊ីខុសច្បាប់ដោយខ្លួនឯង និងធ្វើការងារតាមផ្ទះ កាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៦។ ម្ដាយនិយោជករបស់ពលការិនីបានទទួលមរណៈភាព ដូចនេះនិយោជកបានយល់ព្រមឲ្យគាត់ត្រឡប់មកកម្ពុជាវិញជាមួយនឹងប្រាក់ខែគ្រប់ចំនួន។ ពលការិនីបានទៅស្ថានទូតនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៧ ស្នើសុំជួយឲ្យបានត្រឡប់មកកម្ពុជាវិញ។

ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ម៉ាឡេស៊ី ហើយពលការិនី**ឡា ផល្លី** បានមកដល់អាកាសយានដ្ឋានខេត្ត**សៀមរាប** នៅថ្ងៃទី**០៨** ខែ**កក្កដា** ឆ្នាំ**២០១៧** វេលាម៉ោង **១៤:០៥**នាទី តាមជើងយន្តហោះ **AK540** ។

**(៣)** ពលការិនី ឈ្មោះ **ប៉ែន សុខហេង** អាយុ២៧ឆ្នាំ មកពីស្រុកអូរឬស្សី ខេត្តក្រចេះ បានទៅម៉ាឡេស៊ីដោយខុសច្បាប់តាមរយៈមេខ្យល់ និងធ្វើការងារតាមផ្ទះ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥។

**បញ្ជីរាយនាមពលករនេសាទខ្មែរ ចំនួន១៤នាក់ ធ្វើមាតុភូមិនិវត្តន៍នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៧**

-----------

| | |
|---|---|
| ១. **ឌឹម ភារ៉ា** | កើតថ្ងៃទី ១៦ ខែមេសា ឆ្នាំ១៩៩១ |
| ២. **ជៀម ស៊ីន** | កើតថ្ងៃទី០៧ ខែមីនា ឆ្នាំ១៩៩៨ |
| ៣. **ព្រុំ មានរិត** | កើតថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៨១ |
| ៤. **កង វឿន** | កើតថ្ងៃទី១២ ខែមេសា ឆ្នាំ១៩៨៨ |
| ៥. **ជុន រ៉ាន** | កើតថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ |
| ៦. **ម៉ឹង ហាន់** | កើតថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ |
| ៧. **មាស ពៅ** | កើតថ្ងៃទី០៣ ខែឧសភា ឆ្នាំ១៩៩៧ |
| ៨. **ហួន សី** | កើតថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៩៨ |
| ៩. **ហួន ឈាង** | កើតថ្ងៃទី០២ ខែមករា ឆ្នាំ១៩៩៨ |
| ១០. **ហួន សែ** | កើតថ្ងៃទី០៦ ខែមីនា ឆ្នាំ១៩៨៩ |
| ១១. **សែម សុជា** | កើតថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩៥ |
| ១២. **យ៉ង់ វាសនា** | កើតថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ |
| ១៣. **ជេត ណាង** | កើតថ្ងៃទី០៥ ខែមិថុនា ឆ្នាំ១៩៧៣ |
| ១៤. **កែវ ចិត** | កើតថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៩២ |

ពលការិនីបានទទួលប្រាក់ខែគ្រប់ចំនួនពីនិយោជក ហើយដោយសារចង់ត្រឡប់មកកម្ពុជាវិញ នាងបានទៅស្ថានទូតនៅថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧។

ស្ថានទូតបានសម្របសម្រួលជាមួយការិយាល័យអន្តោប្រវេសន៍ ហើយពលការិនី **ប៉ែន សុខហេង** បានមកដល់អាកាសយានដ្ឋានអន្តរជាតិ**ភ្នំពេញ** នៅថ្ងៃទី**០៨ ខែកក្កដា ឆ្នាំ២០១៧** វេលាម៉ោង **០៧:៣៥** នាទីព្រឹក តាមជើងយន្តហោះ **AK536** ។

ក្នុងអំឡុងពេលរង់ចាំត្រឡប់មកកម្ពុជាវិញ ស្ថានទូតបានផ្តល់កន្លែងស្នាក់នៅ និងអាហារបរិភោគសម្រាប់ពលការិនីទាំងពីរនាក់ខាងលើផងដែរ៕

ភ្នំពេញ, ថ្ងៃទី១០ ខែ កក្កដា ឆ្នាំ ២០១៧

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ